# ចាប់ពីសាលាបឋមសិក្សា ទៅសាលាមធ្យមសិក្សា៖ ជំហានធំបន្ទាប់ទៀត

## ការយល់ដឹងអំពីកិច្ចការសាលារបស់កូនលោកអ្នក







នៅ Year 7 កូនរបស់លោកអ្នកនឹងបានណែនាំឲ្យស្គាល់មុខវិជ្ជាសិក្សាខ្លះៗដែលគេមិនធ្លាប់ពិសោធន៍ពីលើកមុនៗ ហើយនិងមុខវិជ្ជាសិក្សាដទៃទៀតដែលអាចមានដំណោះស្រាយ និងការសង្កត់ធ្ងន់ផ្សេងពីការរៀនសូត្រនៅសាលាបឋមសិក្សា។

គេក៏ត្រូវបានរំពឹងទុកផងដែរឲ្យមានភាពឯករាជ ហើយចេះពឹងលើខ្លួនឯង ជាងកាលពីខ្លួននៅសាលាបឋមសិក្សា។

ដើម្បីឲ្យមានសិទ្ធិទទួល School Certificate របស់ខ្លួន (វិញ្ញាបនបត្រចំពោះការបំពេញដោយជោគជ័យនៃសេចក្ដីតម្រូវផ្នែកកម្មវិធីសិក្សាថ្នាក់ទី៧-១០) នៅចុង Year 10 សិស្សត្រូវសិក្សាមុខវិជ្ជាដូចតទៅចាប់ពី Year 7:

- ភាសាអង់គ្លេស
- គណិតសាស្ត្រ
- វិទ្យាសាស្ត្រ
- ភូមិសាស្ត្រ
- ប្រវត្តិសាស្ត្រ
- ភាសា
- បច្ចេកវិទ្យា
- សិល្បៈផ្នែករូបភាព
- ភ្លេង
- ការចំរើនលូតលាស់ផ្ទាល់ខ្លួន សុខភាព និងការហាត់ប្រាណ (PDHPE)។

សិស្សនៅ Years 7-10 ក៏អាចជ្រើសរើសចេញពីមុខវិជ្ជាជ្រើសរើសបានផងដែរ។ ឧទាហរណ៍នៃមុខវិជ្ជាដែលផ្ដល់ជាទូទៅភាគច្រើននៅ Year 9 និង Year 10 មាន:

- ការសិក្សាពីជនជាតិដើម
- បច្ចេកវិទ្យាខាងកសិកម្ម
- ពាណិជ្ជកម្ម
- របាំ
- ការរៀបចំផែនការ និងបច្ចេកវិទ្យា
- រឿងល្ខោន
- បច្ចេកវិទ្យាខាងម្ហូបចំណី
- បច្ចេកវិទ្យាខាងគូសក្រាហ្វិក
- បច្ចេកវិទ្យាខាងឧស្សាហកម្ម
- បច្ចេកវិទ្យាព័ត៌មាន និងប្រូក្រាមកុំព្យូធើរ
- បច្ចេកវិទ្យាខាងសមុទ្រ និងជលវប្បកម្ម
- ភ្លេង
- គ្រឿងផ្សព្វផ្សាយព័ត៌មានពីរូបភាព និងតួលេខគណិត
- ការសិក្សាពីសកម្មភាពខ្លួនប្រាណ និងកីឡា
- បច្ចេកវិទ្យាខាងតម្បាញ
- សិល្បៈរូបភាព
- ការរៀបចំផែនការរូបភាព
- ការសិក្សាផ្នែកការងារ
- ជំរើសភាសាចំនួន១៧។

មុខវិជ្ជាជ្រើសរើសដែលមានផ្ដល់នៅសាលាមធ្យមសិក្សារដ្ឋនឹងអាស្រ័យទៅលើចំនួនសិស្សដែលចាប់អារម្មណ៍ក្នុងមុខវិជ្ជាណាមួយ ហើយនិងជំនាញការដែលមានផ្ដល់នៅសាលារៀន។ ប្រសិនបើកូនរបស់លោកអ្នកមានទេពកោសល្យ ឬការចាប់អារម្មណ៍ក្នុងផ្នែកណាមួយ លោកអ្នកអាចឆែកមើលនៅតាមសាលាមធ្យមសិក្សាឯកទេសណាមួយរបស់យើង។

### សកម្មភាពក្នុងសាលារៀនដទៃទៀត

សកម្មភាពដទៃខ្លះទៀតដែលសាលាមានផ្ដល់ ដើម្បីគាំទ្រការចំរើនលូតលាស់ផ្នែកសង្គម និងបុគ្គលផ្ទាល់ម្នាក់ៗ មានរួមទាំង:

- ជំនួយសំរាប់វ័យដូចគ្នា និងការសំរុះសំរួលសំរាប់វ័យដូចគ្នា

- អ្នកណែនាំសិស្ស
- កម្មវិធីសំរាប់សិស្សមាននិស្ស័យ និងសិស្សមានទេពកោសល្យ
- កម្មវិធីផ្តល់រង្វាន់ និងការទទួលស្គាល់
- ការអប់រំផ្នែកគ្រឿងញៀន និងសុខភាព
- ការអប់រំប្រឆាំងនឹងការប្រកាន់ពូជសាសន៍
- ការអប់រំផ្នែកអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារក្មេង
- កម្មវិធីការពារទប់ទល់នឹងបទឧក្រិដ្ឋ
- កម្មវិធីសុខភាព និងភាពមានសុខភាពល្អ
- កម្មវិធីផ្លាស់ប្តូរសំរាប់សិស្ស Year 6-7
- ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសិស្ស
- ក្រុមប្រឹក្សាអ្នកតំណាងសិស្ស
- ដំណើរសិក្សាផ្សេងព្រេងតាមជំរំ និងដំណើរសិក្សាកំសាន្តតាមទីវាល។

## កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ

ជាទូទៅកូនរបស់លោកអ្នកនឹងទទួលកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ដែលរៀបចំសំរាប់រៀងរាល់ថ្ងៃរៀននីមួយៗ ហើយកាលណាសិស្សចូលរៀននៅកំរិតថ្នាក់ខ្ពស់ណាស់ នោះសេចក្តីត្រូវការសំរាប់កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ និងការសិក្សានឹងកាន់តែកើនឡើងដែរ។ កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ជួយពង្រឹងកម្លាំងកិច្ចការធ្វើនៅសាលារៀន ហើយជួយពង្រីកជំនាញការទាំងឡាយដូចជាការស្រាវជ្រាវ និងការចេះប្រើនូវពេលវេលា។ វាក៏ជួយធ្វើឲ្យមានទម្លាប់ក្នុងការសិក្សា ការផ្តោតអារម្មណ៍ និងសណ្តាប់ធ្នាប់ផ្ទាល់ខ្លួនផងដែរ។

លោកអ្នកអាចជួយកូនរបស់លោកអ្នកដោយៈ

- យកចិត្តទុកដាក់យ៉ាងសកម្មនៅក្នុងកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះរបស់គេ
- ជួយគេឲ្យចេះរំលែកពេលសំរាប់កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ សំរាប់ថ្ងៃនីមួយៗ
- ផ្តល់នូវទីកន្លែងសមរម្យសំរាប់កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ឬការរៀនសូត្រ ប្រសិនបើអាចធ្វើទៅបាន
- ជួយដល់គ្រូបង្រៀនឲ្យត្រួតពិនិត្យមើលកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ដោយចុះហត្ថលេខាលើកិច្ចការដែលបានធ្វើហើយ ប្រសិនបើមានការស្នើសុំ ហើយត្រូវដឹងអំពីចំនួនកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះដែលសិស្សទទួល
- ធ្វើទំនាក់ទំនងជាមួយគ្រូ ចំពោះកង្វល់ណាមួយអំពីលក្ខណៈកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ឬអំពីដំណោះស្រាយកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះរបស់កូនលោកអ្នក
- លើកទឹកចិត្តកូនរបស់លោកអ្នកឲ្យអាន ហើយយកចិត្តទុកដាក់នឹងព្រឹត្តិការណ៍បច្ចុប្បន្ន
- ផ្តល់ដំណឹងទៅសាលារៀនអំពីកាលៈទេសក្នុងគ្រួសារ ឬសកម្មភាពនានាក្រៅពីកម្មវិធីសិក្សាណាមួយដែលត្រូវការលើកយកមកគិតគូរកាលណាកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះត្រូវបានដាក់ឲ្យ ឬផ្តល់ពិន្ទុ។

សាលារៀននីមួយៗរៀបចំគោលការណ៍ កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះរបស់ខ្លួន ដោយមានការពិគ្រោះជាមួយមាតាបិតា និងអ្នកមើលថែ។ លោកអ្នកអាចទទួលយកគោលការណ៍នេះមួយច្បាប់ពីសាលារៀនរបស់លោកអ្នក។

## របាយការណ៍អំពីការចំរើនលូតលាស់

លោកអ្នកនឹងបានទទួលយ៉ាងហោចណាស់នូវរបាយការណ៍ពីរច្បាប់រៀងរាល់ឆ្នាំ ស្តីពីការចំរើនលូតលាស់របស់កូនលោកអ្នក – តាមធម្មតានៅចុងត្រីមាសទី២ និងទី៤។ នាយកសាលា និងគ្រូបង្រៀន គេទាំងពីរមានចិត្តរីករាយជាខ្លាំងនឹងពិភាក្សាជាមួយលោកអ្នកអំពីការចំរើនលូតលាស់របស់កូនលោកអ្នក។

សាលារៀនជាច្រើនបានរៀបចំការប្រជុំមាតាបិតា / គ្រូ (ធម្មតាធ្វើនៅពេលល្ងាច) ដើម្បីផ្តល់ឱកាសសំរាប់មាតាបិតាឲ្យពិភាក្សាអំពីការចំរើនលូតលាស់របស់កូនខ្លួន ជាមួយគ្រូបង្រៀនរបស់គេ។ សាលាមធ្យមសិក្សាភាគច្រើន លើកទឹកចិត្តមាតាបិតាឲ្យទៅជួប ឬទូរស័ព្ទទៅសាលារៀននៅពេលណាក៏បាន ប្រសិនបើគេចង់ពិភាក្សាអំពីកង្វល់ ឬគំនិតណាមួយដែលគេអាចមាន អំពីការចំរើនលូតលាស់របស់កូនខ្លួន។

ប្រសិនបើត្រូវការ នុះលោកអ្នកអាចស្នើសុំឲ្យមានអ្នកបកប្រែភាសាសំរាប់ការប្រជុំមាតាបិតា / គ្រូ ហើយពេលណាដែលអាចធ្វើទៅបាន សាលារៀននឹងរៀបចំឲ្យមានអ្នកបកប្រែភាសាជូនលោកអ្នកសំរាប់ពេលនោះផងដែរ។

## កិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងជាមួយនាយកសាលា សូមទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាលេខ 131 450 ហើយស្នើសុំអ្នកបកប្រែភាសាជាភាសារបស់លោកអ្នក។ នៅពេលនោះអ្នកបកប្រែភាសានឹងទូរស័ព្ទទៅនាយកសាលា ហើយនិងជួយលោកអ្នកក្នុងការសន្ទនាតាមទូរស័ព្ទ។ លោកអ្នកនឹងមិនបង់ថ្លៃសំរាប់កិច្ចបំរើនេះទេ។

NSW Department of Education

GPO Box 33
Sydney NSW 2001
T 9561 8000

NSW GOVERNMENT Education Public Schools